UNITED NATIONS

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# វឌ្ឍនភាពនៃការអនុវត្តអនុសាសន៍យូភីអ ជុំទី៣ របស់ប្រទេសកម្ពុជា ទាក់ទងនឹងការទទួលបានយុត្តិធម៌

## តើដំណើរការពិនិត្យជាសកលតាមកាលកំណត់ ជាអ្វី?

ដំណើរការពិនិត្យជាសកលតាមកាលកំណត់ («យូភីអ») គឺជាយន្តការមួយរបស់អង្គការសហប្រជាជាតិដែលមានអាណត្តិពិនិត្យកំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋជាសមាជិកទាំងអស់របស់អង្គការសហប្រជាជាតិ។ យន្តការ យូភីអ ជាដំណើរការដឹកនាំដោយរដ្ឋ ដែលរដ្ឋនីមួយៗប្រកាសអំពីវិធានការដែលរដ្ឋបានអនុវត្ត និងការបំពេញកាតព្វកិច្ចក្នុងការធ្វើឱ្យស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសរបស់ខ្លួនបានល្អប្រសើរ។ ប្រទេសកម្ពុជាត្រូវបានពិនិត្យដោយយន្តការ យូភីអ នេះ ក្នុងខែមករា ឆ្នាំ២០១៩ ដែលរដ្ឋសមាជិកបានផ្តល់អនុសាសន៍ចំនួន១៩៨ ហើយប្រទេសកម្ពុជាបានទទួលយកអនុសាសន៍ចំនួន១៧៣ និងកត់សម្គាល់ចំនួន ២៥ អនុសាសន៍ ដោយមានការអនុម័តរបាយការណ៍លទ្ធផលនៃការពិនិត្យដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងកិច្ចប្រជុំលើកទី៤១ ក្នុងខែកក្កដា ឆ្នាំ២០១៩។ នៅក្នុងជុំទី៣ នេះ មានអនុសាសន៍កើនឡើង៦% បើប្រៀបធៀបទៅនឹងជុំទី២។

## ខាងក្រោមគឺជាអនុសាសន៍ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយក៖

១ បន្តកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងបង្កើតប្រព័ន្ធតុលាការឯករាជ្យ ដែលត្រូវបានប្រជាជនជឿជាក់ និងប្រើប្រាស់។ ដើម្បីធ្វើឱ្យសម្រេចបានលើចំណុចនេះ ត្រូវប្រើប្រាស់ជាអតិបរិមានូវគំរូរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ (ជប៉ុន)

២ ធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំអង្គការតុលាការ លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ព្រមទាំងការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីធានា និងការពារឯករាជ្យភាពរបស់តុលាការ។ (បែលហ្ស៊ិក និងអូទ្រីស)

៣ ជម្នះរាល់ឧបសគ្គនានា ដើម្បីទទួលបានយុត្តិធម៌សម្រាប់ស្ត្រីជនរងគ្រោះដោយអំពើហិង្សា។ (អ៊ីរ៉ាក់)

៤ បង្កើនកិច្ចខិតខំប្រឹងប្រែងទ្វេដង ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីក្នុងវិស័យច្បាប់ និងបញ្ចប់ការប្រតិបត្តិអវិជ្ជមាន និងផ្នត់គំនិតបែបរើសអើង ដែលធ្វើឱ្យស្ត្រីកម្ពុជាក្លាយជាជនរងគ្រោះ។ (អ៊ុយក្រាហ្គាយ)

៥ ផ្តល់វគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចស្តីពីនីតិវិធីផ្តន្ទាទោសលើករណីអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ដល់មន្ត្រី អនុវត្តច្បាប់ និងមន្ត្រីតុលាការ។ (សាធារណៈរដ្ឋម៉ុលដាវី)

៦ បែងចែកធនធានមនុស្ស និងហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ ដើម្បីបង្កើតមជ្ឈមណ្ឌលផ្តល់សេវាច្រកចេញចូលតែមួយ ឱ្យបានយ៉ាងតិច៥មណ្ឌល នៅត្រឹមឆ្នាំ២០២៤ សម្រាប់ផ្តល់សេវាកម្មគាំទ្រដោយឥតបង់ថ្លៃជូនជនរងគ្រោះនៃអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ។ (អូស្ត្រាលី)

៧ ធ្វើការស៊ើបអង្កេតឱ្យបានគ្រប់ជ្រុងជ្រោយអំពីករណីអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ ព្រមទាំងធានាថា ជនល្មើសត្រូវបានផ្តន្ទាទោស ហើយជនរងគ្រោះត្រូវទទួលបានសំណងសមរម្យ។(សាធារណរដ្ឋម៉ូដូវ៉ា)

៨ ធ្វើកំណែទម្រង់ច្បាប់ជាតិ ដើម្បីពង្រឹងការការពារស្ត្រីនិងកុមារ ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ។ (សហព័ន្ធរុស្ស៊ី)

៩ ពង្រឹងយន្តការតុលាការ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាផ្លូវភេទ និងក្នុងគ្រួសារ និងការជួញដូរមនុស្ស ព្រមទាំង អនុវត្តកម្មវិធីលើកកម្ពស់ការយល់ដឹង និងការអប់រំអំពីបញ្ហាទាំងនេះ(តូហ្គូ)។

## ចំណុចវឌ្ឍនភាព

ចាប់តាំងពីការទទួលអនុសាសន៍ទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានវឌ្ឍនភាពមួយចំនួនដូចខាងក្រោម៖

- រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតច្បាប់ពាក់ព័ន្ធវិស័យតុលាការ និងបានបង្កើតអង្គភាពរដ្ឋបាលតុលាការ ដែលពុំមានអំណាចជ្រៀតជ្រែកកិច្ចការ និងជះឥទ្ធិពលលើសិទ្ធិជម្រះក្តីរបស់ចៅក្រម។
- ក្រសួងយុត្តិធម៌ក្នុងកិច្ចសហការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា កំពុងដំណើរការពិនិត្យឡើងវិញនូវច្បាប់ពាក់ទងនឹងតុលាការ រួមមាន ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម។
- រាជរដ្ឋាភិបាលបានដាក់ចេញយុទ្ធសាស្ត្រដើម្បីកំណើនការងារ ពង្រឹងភាពអង់អាចក្លាហាន សមភាព និងប្រសិទ្ធភាព» ដោយទទួលស្គាល់តួនាទី និងតម្រូវការផ្នែកសង្គមសេដ្ឋកិច្ចរបស់ស្ត្រី ព្រមទាំងបានដាក់ចេញនូវគោលនយោបាយមួយចំនួនទាក់ទងនឹងសមភាពយេនឌ័រ និងអំពើហិង្សាលើស្ត្រី
- រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តផែនការសកម្មភាព និងគោលនយោបាយក្នុងការទប់ស្កាត់អំពើហិង្សាលើកុមារ។

## ចំណុចត្រូវបន្តអនុវត្ត

ទោះបីជាទទួលបានវឌ្ឍនភាពមួយចំនួនក្តី តែរដ្ឋាភិបាលត្រូវបន្តអនុវត្តលើចំណុចមួយចំនួនទៀតដូចជា៖

- បន្តពិនិត្យច្បាប់ពាក់ទងនឹងតុលាការ ជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
- បន្តលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនកិច្ចប្រឹងប្រែងក្នុងការលុបបំបាត់អំពើហិង្សាលើស្ត្រី
- បណ្តុះបណ្តាល និងកសាងសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់។ល។

ម.ស.ម.ក សូមរំឭកអំពីកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋាភិបាលក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងស្នើឱ្យរដ្ឋាភិបាលអនុវត្តអនុសាសន៍ដែលបានទទួលយកទាំងអស់ឱ្យបានមុនយូភីអជុំបន្ទាប់។ ម.ស.ម.ក ព្រមទាំងស្នើឱ្យរដ្ឋាភិបាលពិចារណាទទួលយកអនុសាសន៍ដែលកត់សម្គាល់ទាំងអស់នៅក្នុងជុំទីបួនផងដែរ៕

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
@CCHRCambodia
@CCHRCambodia
cchrcambodia.org
sithi.org
ខែកក្កដា ឆ្នាំ២០២៣

CC BY NC SA